ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



# ផែនការសកម្មភាព ៣ ឆ្នាំរំកិល ២០២៣-២០២៥

# គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល

**២០២៣-២០២៥**

*រៀបចំដោយ*

*គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល*

**២០២៣**

# អារម្ភកថា

រាជរដ្ឋាភិបាល បានចាត់ទុកបច្ចេកវិទ្យាឌីជីថល ជាឧបករណ៍មួយដ៏មានសារៈសំខាន់ ក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងប្រសិទ្ធភាពការងាររដ្ឋបាលរបស់ខ្លួន ដែលជាការត្រៀមខ្លួនសម្រាប់ការកសាងសេដ្ឋកិច្ចឌីជីថល និងការឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្ម ៤.០ ។ ការរីករាលដាលនៃវិបត្តិជំងឺឆ្លងកូវីដ-១៩ បានរំលេចឡើងកាន់តែច្បាស់បន្ថែមទៀត អំពីសារៈសំខាន់របស់បច្ចេកវិទ្យាឌីជីថល ដែលមិនអាចខ្វះបាន ដែលតម្រូវឱ្យមន្ត្រីរាជការ បុគ្គលិកទាំងក្នុងវិស័យរដ្ឋ និងវិស័យឯកជន បំពេញការងារពីចម្ងាយ និងផ្តល់សេវាពីចម្ងាយ ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលបានប្រែក្លាយពីវិបត្តិទៅជាឱកាសដោយចាប់យកការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងប្រសិទ្ធភាពការងារ ។

ជាការឆ្លើយតប, រាជរដ្ឋាភិបាល បានដាក់ឱ្យអនុវត្តនូវ **ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥** ដោយមានចក្ខុវិស័យ "**កសាងសេដ្ឋកិច្ច និងសង្គមឌីជីថលរស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញទទួលយក និងបរិវត្តកម្មឌីជីថលនៅក្នុងគ្រប់តួអង្គសង្គម ទាំងរដ្ឋ ទាំងពលរដ្ឋ និងទាំងធុរជន ដើម្បីជំរុញសន្ទុះកំណើនសេដ្ឋកិច្ចថ្មី និងលើកកម្ពស់សុខុមាលភាពសង្គម តាមគន្លងប្រក្រតីភាពថ្មី**" ។ ក្របខណ្ឌគោលនយោបាយនេះ មានរយៈពេល ១៥ ឆ្នាំ ដោយបែងចែកជា បី (៣) ដំណាក់កាល ដែលផ្តោតលើ ការកសាងមូលដ្ឋានគ្រឹះ និងការចាប់យកឌីជីថល (២០២១-២០២៥), ការចាប់យក និងការធ្វើបរិវត្តកម្មឌីជីថល (២០២៦-២០៣០) និងការធ្វើបរិវត្តកម្មឌីជីថល (២០៣១-២០៣៥) ។ ក្នុងនោះ, ក្របខណ្ឌនេះ បានដាក់ចេញនូវ គ្រឹះ ចំនួន ២ រួមមាន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល និង ការកសាងទំនុកចិត្ត និងភាពជឿជាក់លើប្រព័ន្ធឌីជីថល និងសសរស្តម្ភ ចំនួន ៣ រួមមាន ការកសាងពលរដ្ឋឌីជីថល, ការកសាងរដ្ឋាភិបាលឌីជីថល និងការជំរុញធុរកិច្ចឌីជីថល ដើម្បីកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ។ តាមរយៈក្របខណ្ឌខាងលើ, ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និងសង្គមឌីជីថល ត្រូវបានបង្កើតឡើងដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាប្រធាន ដើម្បីដឹកនាំ និងសម្រេចការងារសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ។ ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និងសង្គមឌីជីថល មានអគ្គលេខាធិការដ្ឋានចំនួន ១ និង គណៈកម្មាធិការ ចំនួន ៣ រួមមាន ៖ ១. គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល, ២. គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល និង ៣. គណៈកម្មាធិការសន្តិសុខឌីជីថល ។

ដើម្បីសម្រេចបានចក្ខុវិស័យខាងលើ, គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល បានដាក់ចេញនូវ **ផែនការសកម្មភាព ៣ ឆ្នាំរំកិល ២០២៣-២០២៥ របស់គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល** ដែលមានគោលបំណងសម្រេចឱ្យបាននូវការអនុវត្តវិធានការគោលនយោបាយគន្លឹះ ដើម្បីជួយពន្លឿនការកសាងមូលដ្ឋានគ្រឹះ និងការចាប់យកឌីជីថលក្នុងដំណាក់កាលទី១ នៃការធ្វើបរិវត្តកម្មឌីជីថលកម្ពុជា ត្រឹមឆ្នាំ ២០២៥ ។ ផែនការសកម្មភាព ៣ ឆ្នាំរំកិល នេះ មានវិធានការគោលនយោបាយគន្លឹះចំនួន **៥៣** ក្រោមគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល និង ចំនួន **៩** ក្រោមការសម្របសម្រួលរួមគ្នារបស់គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល និងគណៈកម្មាធិការរដ្ឋាភិបាល

ឌីជីថល។ ក្នុងនោះ, អភិក្រមនៃការរៀបចំផែនការសកម្មភាពនេះ គឺក្នុង**ជំហានដំបូង ត្រូវជ្រើសយក "អភិក្រមពីលើចុះក្រោម (Top-Down Approach)"** ដោយដាក់ចេញនូវតារាងសកម្មភាពអាទិភាពបែបចង្អុលបង្ហាញ (Indicative List) ដាក់ជូនក្រសួង-ស្ថាប័នពាក់ព័ន្ធ និង **ក្នុងជំហានទី២ ត្រូវអនុវត្ត "អភិក្រមពីក្រោមឡើងលើ (Bottom-Up Approach)"** ដោយត្រូវបញ្ជូនតារាងផែនការសកម្មភាពលម្អិតទៅជូនក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីផ្តល់ធាតុចូលឱ្យស្របតាមសកម្មភាពអាទិភាព និងក្របខណ្ឌពេលវេលានៃការអនុវត្តរបស់ក្រសួង-ស្ថាប័ននីមួយៗ ទៅតាមឆ្នាំនីមួយៗ ។ បន្ថែមពីនេះ, គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល ក៏នឹងដាក់ចេញយន្តការតាមដាន និងវាយតម្លៃច្បាស់លាស់សម្រាប់ការតាមដានការអនុវត្តរបស់ក្រសួង-ស្ថាប័នផងដែរ ។ ជារួម, **ផែនការសកម្មភាព ៣ ឆ្នាំរំកិល ២០២៣-២០២៥ របស់គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល** នឹងក្លាយជាផែនទីបង្ហាញផ្លូវក្នុងការអនុវត្តក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាសម្រាប់រយៈពេល ៣ ឆ្នាំ ខាងមុខ ។

ជាទីបញ្ចប់, ក្នុងនាមគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល, ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមយ៉ាងសកម្ម និងផ្តល់កិច្ចសហការល្អប្រសើរជាមួយអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រុមការងារនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល ទាំងអស់ ដែលបានខិតខំប្រឹងប្រែង និងចូលរួមរៀបចំយ៉ាងសកម្ម ឱ្យសម្រេចបាននូវ **ផែនការសកម្មភាព ៣ ឆ្នាំរំកិល ២០២៣-២០២៥ របស់គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល** នេះឡើង ។

ថ្ងៃ សុក្រ ១១ រោច ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល**

គ.ស.ធ.ឌ.

DIGITAL ECONOMY AND BUSINESS COMMITTEE

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# មាតិកា


**១. សេចក្ដីផ្ដើម ............................................................................................ ១**

**២. ក្របខណ្ឌរួមនៃផែនការសកម្មភាព ....................................................................... ១**

២.១. គោលបំណង គោលដៅ និងវិសាលភាព ........................................................................ ១

២.២. អភិក្រមនៃការរៀបចំសកម្មភាព .................................................................................. ២

២.៣. ការតាមដាន និងវាយតម្លៃការអនុវត្ត ........................................................................... ៣

**៣. សេចក្ដីសន្និដ្ឋាន ............................................................................................ ៣**

**តារាងសង្ខេប ................................................................................................. ៥**

**ឧបសម្ព័ន្ធ ១. អភិក្រមនៃការរៀបចំផែនការសកម្មភាព ៣ ឆ្នាំរំកិល (២០២៣-២០២៥) ............. ៦**

**ឧបសម្ព័ន្ធ ២. បញ្ជីអក្សរកាត់នៃក្រសួង-ស្ថាប័ន ........................................................ ៤៩**

## ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវ **ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥** ដើម្បីគាំទ្រដល់ការធ្វើបរិវត្តកម្មឌីជីថលសេដ្ឋកិច្ច និងសង្គមកម្ពុជា ។ ក្របខណ្ឌនេះ មានរយៈពេល ១៥ ឆ្នាំ ដោយបែងចែកជា បី (៣) ដំណាក់កាល ដែលផ្តោតលើ ការកសាងមូលដ្ឋានគ្រឹះ និងការចាប់យកឌីជីថល (២០២១-២០២៥), ការចាប់យក និងការធ្វើបរិវត្តកម្មឌីជីថល (២០២៦-២០៣០) និងការធ្វើបរិវត្តកម្មឌីជីថល (២០៣១-២០៣៥) ។ ក្នុងនោះ, ក្របខណ្ឌគោលនយោបាយនេះ បានដាក់ចេញនូវ គ្រឹះ ចំនួន ២ រួមមាន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល និង ការកសាងទំនុកចិត្ត និងភាពជឿជាក់លើប្រព័ន្ធឌីជីថល និងសសរស្តម្ភ ចំនួន ៣ រួមមាន ការកសាងពលរដ្ឋឌីជីថល, ការកសាងរដ្ឋាភិបាលឌីជីថល និងការជំរុញធុរកិច្ចឌីជីថល ដើម្បីកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ។

ដើម្បីធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធភាពខ្ពស់, ក្របខណ្ឌគោល-នយោបាយខាងលើនេះ ក៏បានដាក់ចេញនូវយន្តការស្ថាប័ន ដោយបានបង្កើតនូវ ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និងសង្គមឌីជីថល ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាប្រធាន ដើម្បីដឹកនាំ និងសម្រេចការងារសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ។ ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និងសង្គមឌីជីថល មានអគ្គលេខាធិការដ្ឋាន ចំនួន ១ និង គណៈកម្មាធិការ ចំនួន ៣ រួមមានៈ ១. គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល, ២. គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល និង ៣. គណៈកម្មាធិការសន្តិសុខឌីជីថល ។ ក្របខណ្ឌគោលនយោបាយនេះ មានរយៈពេលអនុវត្ត ចំនួន ១៥ ឆ្នាំ និងមានវិធានការគោលនយោបាយគន្លឹះសរុបចំនួន ១៣៩ ដែលត្រូវបានដាក់ចេញ ។ ដោយឡែក, ចំពោះគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល មានវិធានការគោល-នយោបាយគន្លឹះសរុបចំនួន ៨០ និងមានក្រសួង-ស្ថាប័នចំនួន ២២ ដែលត្រូវសម្របសម្រួល និងចូលរួមអនុវត្ត ។ ក្នុងន័យនេះ, ការរៀបចំផែនការសកម្មភាពលម្អិតក្រោមក្របខណ្ឌគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល មានភាពចាំបាច់ក្នុងការដឹកនាំ និងសម្របសម្រួលការអនុវត្តវិធានការគោល-នយោបាយគន្លឹះរបស់ក្រសួង-ស្ថាប័ន ឱ្យសម្រេចបាននូវប្រសិទ្ធភាពខ្ពស់ និងស្របតាមក្របខណ្ឌនៃពេលវេលា ។

## ២. ក្របខណ្ឌរួមនៃផែនការសកម្មភាព

### ២.១. គោលបំណង គោលដៅ និងវិសាលភាព

**ផែនការសកម្មភាព ៣ ឆ្នាំរំកិល ២០២៣-២០២៥ របស់គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល** មានគោលបំណងសម្រេចឱ្យបាននូវការអនុវត្តវិធានការគោលនយោបាយគន្លឹះ ដើម្បីជួយពន្លឿនការកសាងមូលដ្ឋានគ្រឹះ និងការចាប់យកឌីជីថលក្នុងដំណាក់កាលទី១ នៃការធ្វើបរិវត្តកម្មឌីជីថលកម្ពុជា ។ ដើម្បីសម្រេចបានគោលបំណងនេះ, ផែនការសកម្មភាព ៣ ឆ្នាំរំកិល នេះ មានគោលដៅ កំណត់ក្រប-ខណ្ឌទស្សនាទានរួម សម្រាប់សម្របសម្រួល និងជំរុញការអនុវត្តវិធានការគោលនយោបាយគន្លឹះនៅក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ក្រោមការទទួលខុសត្រូវរបស់គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល ប្រកបដោយប្រសិទ្ធភាព សក្តិសិទ្ធភាព និង

ភាពស៊ីសង្វាក់គ្នារបស់ក្រសួង-ស្ថាប័ន សំដៅរួមចំណែកក្នុងការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ។ ដោយផ្អែកលើក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥, ក្របខណ្ឌពេលវេលាមានជាអាទិ៍ ៖ រយៈពេលខ្លី រយៈពេលខ្លី-មធ្យម រយៈពេលមធ្យម រយៈពេលមធ្យម-វែង រយៈពេលខ្លី-វែង និងរយៈពេលខ្លី-វែង(ជាប្រចាំ) ។

ផែនការសកម្មភាព ៣ ឆ្នាំរំកិលនេះ **គ្របដណ្តប់លើវិធានការគោលនយោបាយរយៈពេលខ្លី រយៈពេលខ្លី-មធ្យម រយៈពេលខ្លី-វែង**[1] **និងរយៈពេលខ្លី-វែង(ជាប្រចាំ)**[2] ដែលស្ថិតក្រោមក្របខណ្ឌគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល និងក្រោមការសម្របសម្រួលរួមគ្នារបស់គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល និងគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល ដោយមិនរាប់បញ្ចូលវិធានការគោលនយោបាយរយៈពេលមធ្យម និងរយៈពេលមធ្យម-វែង នោះទេ ។ ក្នុងនោះ, ផែនការសកម្មភាពនេះ ដាក់ចេញនូវសកម្មភាពគោលនយោបាយគន្លឹះលម្អិតនៃវិធានការគោលនយោបាយគន្លឹះនីមួយៗ ហើយចំពោះក្របខណ្ឌពេលវេលាលម្អិត ក្នុងដំណាក់កាលដំបូងផ្តោតលើតែរយៈពេល ៣ ឆ្នាំ នៃការអនុវត្ត ចាប់ពី ឆ្នាំ ២០២៣ ដល់ ឆ្នាំ ២០២៥ ដោយមិនរាប់បញ្ចូល ឆ្នាំ ២០២១ និង ឆ្នាំ ២០២២ នោះទេ ដោយហេតុថា ក្នុងរយៈពេលពីរឆ្នាំដំបូងនេះ បានកន្លងផុតរួចហើយ ។ ជារួម, ផែនការសកម្មភាព ៣ ឆ្នាំរំកិល នេះ មានវិធានការគោលនយោបាយគន្លឹះចំនួន **៥៣** ក្រោមគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល និង ចំនួន **៩** ក្រោមការសម្របសម្រួលរួមគ្នារបស់គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល និង គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល ។

## ២.២. អភិក្រមនៃការរៀបចំសកម្មភាព

ផែនការសកម្មភាព ៣ ឆ្នាំរំកិល នេះ ត្រូវបានរៀបចំឡើងស្ថិតក្រោមក្របខណ្ឌគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល ដោយក្នុងនោះ ដោយសារពេលវេលាមានកំណត់ អភិក្រមនៃការរៀបចំក្នុង**ជំហានដំបូង ត្រូវជ្រើសយក "អភិក្រមពីលើចុះក្រោម (Top-Down Approach)"** ដោយដាក់ចេញនូវតារាងសកម្មភាពអាទិភាពបែបចង្អុលបង្ហាញ (Indicative List) ដាក់ជូនក្រសួង-ស្ថាប័ន និង **ក្នុងជំហានទី២ ត្រូវអនុវត្ត "អភិក្រមពីក្រោមឡើងលើ (Bottom-Up Approach)"** ដោយត្រូវបញ្ជូនតារាងផែនការសកម្មភាពលម្អិតទៅជូនក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលទទួលបន្ទុកអនុវត្តក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល ដើម្បីផ្តល់ធាតុចូលឱ្យស្របតាមសកម្មភាពគន្លឹះអាទិភាព និងក្របខណ្ឌពេលវេលានៃការអនុវត្តរបស់ក្រសួង-ស្ថាប័ននីមួយៗទៅតាមឆ្នាំនីមួយៗ ដោយមានលក្ខណៈជាផែនការសកម្មភាពបែបរំកិលជាបន្តបន្ទាប់ ។ ក្នុងនោះ, ក្រសួង-ស្ថាប័ន ត្រូវផ្តល់យោបល់ និងធាតុចូលមកអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល ដើម្បីរៀបចំសេចក្តីព្រាងចុងក្រោយមួយដែលមានលក្ខណៈពេញលេញ និងគ្រប់ជ្រុងជ្រោយ ។ ក្នុងន័យនេះ, ផែនការសកម្មភាព ៣ ឆ្នាំរំកិល នេះបានដាក់ចេញនូវសកម្មភាព ដែលត្រូវអនុវត្តដោយក្រសួង-ស្ថាប័នពាក់ព័ន្ធ ចាប់ពីឆ្នាំ ២០២៣ ដល់ ឆ្នាំ ២០២៥ ដូចមានជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ១ ។ ផែនការសកម្មភាព

[1] វិធានការគោលនយោបាយរយៈពេលខ្លី-វែង គឺជាវិធានការដែលត្រូវអនុវត្តរយៈពេលវែង តែមិនអនុវត្តជាប្រចាំទេ

[2] វិធានការគោលនយោបាយរយៈពេលខ្លី-វែង (ជាប្រចាំ) គឺជាវិធានការដែលត្រូវអនុវត្តរយៈពេលវែង ជាបណ្តើរៗ និងអនុវត្តជាប្រចាំតែម្តង

៣ ឆ្នាំរំកិល នេះ មានសកម្មភាពមួយចំនួនត្រូវចាប់ផ្ដើមអនុវត្តដំណាលគ្នា, សកម្មភាពមួយចំនួនមានលក្ខណៈបំពេញឱ្យគ្នា និងសកម្មភាពមួយចំនួនទៀតជាការបើកផ្លូវឱ្យសកម្មភាពផ្សេងទៀតអាចអនុវត្តបាន ។

ផែនការសកម្មភាព ៣ ឆ្នាំរំកិល នេះ នឹងត្រូវធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំដើម្បីបូកសរុបលទ្ធផលនៃការអនុវត្តសកម្មភាពដែលសម្រេចបានក្នុងឆ្នាំ និងមានមូលដ្ឋានកំណត់សកម្មភាពណាខ្លះដែលត្រូវរំកិល ឬ យោងទៅអនុវត្តក្នុងឆ្នាំបន្ទាប់ និងសកម្មភាពណាខ្លះដែលត្រូវបន្ថែម ។ ជារួម, ឯកសារនេះ ផ្ដោតលើវិធានគោលនយោបាយដែលស្ថិតក្រោមសមត្ថកិច្ច និងការសម្របសម្រួលរបស់គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល ប៉ុណ្ណោះ ។

### ២.៣. ការតាមដាន និងវាយតម្លៃការអនុវត្ត

ដើម្បីធានាប្រសិទ្ធភាពនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ, ក្រសួង-ស្ថាប័នទទួលបន្ទុកមានតួនាទីរៀបចំរបាយការណ៍រួម (ត្រីមាស, ឆមាស, ប្រចាំឆ្នាំ) ដោយធ្វើការវាយតម្លៃ (គិតជា %) នៃការសម្រេចបានការអនុវត្តវិធានការគោលនយោបាយនោះ ។ ក្នុងនោះ, ចំពោះការតាមដាន និងវាយ-តម្លៃការអនុវត្តលម្អិត ក្រសួង-ស្ថាប័ន ត្រូវរៀបចំរបាយការណ៍ និងសូចនាករសមិទ្ធកម្មគន្លឹះ ស្របតាម **ក្របខណ្ឌតាមដាន និងវាយតម្លៃសេដ្ឋកិច្ច និងធុរកិច្ចឌីជីថលកម្ពុជា** ដើម្បីជំរុញការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តសកម្មភាពប្រកបដោយប្រសិទ្ធភាព និងសក្ដិសិទ្ធភាពខ្ពស់ ។ បន្ថែមពីនេះ ក៏ត្រូវគិតគូរពីការពង្រឹងសមត្ថភាពស្ថិតិដើម្បីបង្កើតសំណុំទិន្នន័យពាក់ព័ន្ធទាំងពីស្ថិតិរដ្ឋបាល និងការស្ទង់មតិ ដើម្បីឆ្លើយតបនឹងក្របខណ្ឌតាមដាន និងវាយតម្លៃសេដ្ឋកិច្ច និងធុរកិច្ចឌីជីថលកម្ពុជា ។ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល[3] ដើរតួនាទីជាអង្គភាពសម្របសម្រួលក្នុងការរៀបចំរបាយការណ៍វឌ្ឍនភាព, ផែនការសកម្មភាពឆ្នាំបន្ទាប់ និងការរៀបចំកិច្ចប្រជុំរបស់គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល តាមការចាំបាច់ និងការកោះប្រជុំរបស់ប្រធានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល ។

## ៣. សេចក្ដីសន្និដ្ឋាន

**ផែនការសកម្មភាព ៣ ឆ្នាំរំកិល ២០២៣-២០២៥ របស់គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល** នឹងក្លាយជាផែនទីបង្ហាញផ្លូវក្នុងការអនុវត្តក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាសម្រាប់រយៈពេល ៣ ឆ្នាំ ខាងមុខ ។ ការចូលរួម និងកិច្ចសហការយ៉ាងជិតស្និទ្ធលើការអនុវត្តផែនការសកម្មភាពរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធប្រកបដោយការទទួលខុសត្រូវខ្ពស់ គឺជាគន្លឹះនៃភាពជោគជ័យក្នុងការសម្រេចឱ្យបាននូវការអនុវត្តផែនការសកម្មភាព ៣ ឆ្នាំរំកិល នេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។ ទន្ទឹមនេះ, ការតាមដានការអនុវត្តផែនការសកម្មភាពនេះ ត្រូវឆ្លុះបញ្ចាំងក្នុង **ក្រប-ខណ្ឌតាមដាន និងវាយតម្លៃសេដ្ឋកិច្ច និងធុរកិច្ចឌីជីថលកម្ពុជា** ដែលជាយន្តការសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាពរបស់ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង

[3] គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល ត្រូវបានបង្កើតឡើងតាមអនុក្រឹត្យលេខ ២២០ អនក្រ.បក ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០២១ និងមានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ។

សង្គមឱីជីថលកម្ពុជា ២០២១-២០៣៥ ក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល ។

ដូចនេះ ការសម្រេចបាននូវការអនុវត្តវិធានការគោលនយោបាយតាមរយៈផែនការសកម្មភាព ៣ ឆ្នាំរំកិល នេះ នឹងជួយពន្លឿនការកសាងមូលដ្ឋានគ្រឹះ និងការចាប់យកឌីជីថល នៅក្នុងដំណាក់កាល ទី ១ នៃការធ្វើបរិវត្តកម្មឌីជីថលនៅកម្ពុជា ។

# តារាងសង្ខេប
# ផែនការសកម្មភាព ៣ ឆ្នាំរំកិល ២០២៣-២០២៥
# របស់គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល

| ល.រ. | អាទិភាពជាយុទ្ធសាស្ត្រ | ក្រោមការសម្របសម្រួលរបស់ គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រោមការសម្របសម្រួលរួមរបស់ គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល និង គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល |
|---|---|---|---|
| I. | **ហេដ្ឋារចនាសម្ព័ន្ធ** | **១៥** | **១** |
| | ក. ការតភ្ជាប់ឌីជីថល | ៣ | ១ |
| | ខ. ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ និង ប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល | ៩ | ០ |
| | គ. ឡូហ្ស៊ីស្ទិក និង ការដឹកជញ្ជូនគោលដៅចុងក្រោយ | ៣ | ០ |
| II. | **ទំនុកចិត្ត និង ភាពជឿជាក់លើប្រព័ន្ធឌីជីថល**[4] | **០** | **០** |
| | ក. ក្របខណ្ឌច្បាប់ | ០ | ០ |
| | ខ. ការគ្រប់គ្រងសន្តិសុខសាយប័រ | ០ | ០ |
| III. | **ពលរដ្ឋឌីជីថល** | **៦** | **៣** |
| | ក. ភាពជាអ្នកដឹកនាំឌីជីថល | ២ | ២ |
| | ខ. បណ្តុំធនធានមនុស្សដែលមានទេពកោសល្យឌីជីថល | ២ | ១ |
| | គ. ពលរដ្ឋឌីជីថល | ២ | ០ |
| IV. | **រដ្ឋាភិបាលឌីជីថល** | **២** | **៤** |
| | ក. រដ្ឋាភិបាល និង សេវាសាធារណៈឌីជីថល | ០ | ០ |
| | ខ. គន្លឹះជំរុញការអនុវត្តឌីជីថល | ២ | ៣ |
| | គ. អភិបាលកិច្ចផ្អែកលើទិន្នន័យ | ០ | ១ |
| V. | **ធុរកិច្ចឌីជីថល** | **២០** | **០** |
| | ក. បរិវត្តកម្មឌីជីថលសហគ្រាស | ៨ | ០ |
| | ខ. ប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព និង ធុរកិច្ចថ្មី | ៨ | ០ |
| | គ. ខ្សែច្រវាក់តម្លៃឌីជីថល | ៤ | ០ |
| VI. | **ផលប៉ះពាល់បណ្តាលមកពីបរិវត្តកម្មឌីជីថល** | **៦** | **១** |
| | ក. សេដ្ឋកិច្ច និង សង្គម | ៣ | ១ |
| | ខ. ប្រព័ន្ធសារពើពន្ធ | ៣ | ០ |
| VII. | **កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឌីជីថលក្នុងតំបន់** | **៤** | **០** |
| | **សរុប** | **៥៣** | **៩** |

[4] វិធានការគោលនយោបាយគន្លឹះក្នុងផ្នែកទី២ ស្ថិតនៅក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការសន្តិសុខឌីជីថល

## ឧបសម្ព័ន្ធ ១. អតិក្រមនៃការរៀបចំផែនការសកម្មភាព ៣ ឆ្នាំរំកិល ២០២៣-២០២៥

| ល.រ* | ទិសដៅគោលនយោបាយ / វិធានការគោលនយោបាយគន្លឹះ | ល.ស** | ក្រសួង-ស្ថាប័ន | សូចនាករសមិទ្ធកម្មគន្លឹះ | ២០២៣ | | | | ២០២៤ | | | | ២០២៥ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| | **ក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល** | | | | | | | | | | | | | | | |
| | **I. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល ៖ ការតភ្ជាប់ឌីជីថល, ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ និង ប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល, និង ឡូហ្ស៊ីស្ទិក និង ការដឹកជញ្ជូនគោលដៅចុងក្រោយ** | | | | | | | | | | | | | | | |
| | **ក. ការតភ្ជាប់ឌីជីថល** ផ្តោតលើ ៖ ការកសាងហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិតល្បឿនលឿន, ការកសាងហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ ប្រកបដោយសមត្ថភាពសម្រាប់ត្រៀមខ្លួនឆ្លើយតបទៅនឹងការវិវឌ្ឍឥតឈប់ឈរនៃបច្ចេកវិទ្យា, និង ការកសាងហេដ្ឋារចនាសម្ព័ន្ធផ្នែករឹង និង ទន់ ដែលគាំទ្រដល់ការរស់នៅបែបឆ្លាតរបស់ប្រជាពលរដ្ឋ ។ | | | | | | | | | | | | | | | |
| ១ | រៀបចំគោលនយោបាយលើកទឹកចិត្តផ្អែកលើពន្ធលើការវិនិយោគហេដ្ឋា-រចនាសម្ព័ន្ធផ្នែកទិន្នន័យ ( Data and Cloud Computing Facility ) ក្នុងគោលដៅលើកកម្ពស់ការបង្កើតមជ្ឈមណ្ឌលទិន្នន័យ ( Data Center ) នៅក្នុងស្រុកឱ្យបានច្រើន (វិធានការគោលនយោបាយនេះត្រូវបានដកចេញតែម្តងតបតាមការស្នើសុំរបស់អគ្គនាយកដ្ឋានពន្ធដារ ) | | | | | | | | | | | | | | | |
| ២ | បង្កើតក្របខណ្ឌតាមដាន និង វាយតម្លៃអំពីប្រសិទ្ធភាពចំណាយលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល | ១០ | -ក.ស.ហ.វ<br>-ក.ប.ទ | ក្របខណ្ឌតាមដាន និង វាយតម្លៃពីប្រសិទ្ធភាពចំណាយលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលត្រូវបានបង្កើត | x | x | x | x | | | | | | | | |

* ល.រ ជាលេខរៀងនៃផែនការសកម្មភាព ៣ ឆ្នាំរំកិល

** ល.ស ជាលេខសម្គាល់វិធានការគោលនយោបាយគន្លឹះនៃក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥

ចំណាំ ៖ ចំពោះសកម្មភាពមួយចំនួនដែលត្រូវអនុវត្តក្នុងរូបភាពអន្តរស្ថាប័នរវាងក្រសួង-ស្ថាប័នចំនួន ពីរ ឬ ច្រើន, ក្រសួង-ស្ថាប័ន ១ អាចដឹកនាំសម្របសម្រួលក្នុងការអនុវត្តសកម្មភាពនោះ និងត្រូវរៀបចំជារបាយការណ៍បញ្ជូនមកអគ្គលេខាធិការដ្ឋាន គ.ស.ធ.ឌ. ដើម្បីបូកសរុបមុននឹងដាក់ជូន គ.ស.ធ.ឌ. ពិនិត្យ និង អនុម័ត ។

| ល.រ* | ទិសដៅគោលនយោបាយ / វិធានការគោលនយោបាយគន្លឹះ | ល.ស** | ក្រសួង-ស្ថាប័ន | សូចនាករ សមិទ្ធកម្មគន្លឹះ | ២០២៣ | | | | ២០២៤ | | | | ២០២៥ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| | បង្កើតក្រុមការងារអន្តរក្រសួងទទួលបន្ទុករៀបចំក្របខណ្ឌ | | | ឯកសារបង្កើតក្រុមការងារ | x | | | | | | | | | | | |
| | ស្រាវជ្រាវ និងរៀបចំសេចក្ដីព្រាងបឋម | | | សេចក្ដីព្រាងបឋម | x | x | | | | | | | | | | |
| | រៀបចំកិច្ចប្រជុំពិគ្រោះយោបល់អន្តរក្រសួង និងគ្រប់ភាគីពាក់ព័ន្ធ ដើម្បីកែសម្រួលសេចក្តីព្រាងឡើងវិញ | | | របាយការណ៍កិច្ចប្រជុំ | | x | x | | | | | | | | | |
| | រៀបចំសេចក្ដីព្រាងចុងក្រោយ ជូនគណៈកម្មាធិការពិនិត្យ និងសម្រេច | | | សេចក្ដីព្រាងបញ្ចប់ | | | | x | | | | | | | | |
| | រៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងប្រកាសដាក់ឱ្យអនុវត្ត ដោយមានការចូលរួមពីក្រសួង-ស្ថាប័ន និងវិស័យឯកជន | | | របាយការណ៍សិក្ខាសាលា | | | | x | | | | | | | | |
| ៣ | ជំរុញយន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជន (PPP) ក្នុងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដើម្បីបំពេញគម្លាតនៃតម្រូវការវិនិយោគរបស់វិស័យឯកជន | ១១ | -ក.ស.ហ.វ<br>-ក.ប.ទ<br>-ក្រ.ឱ.វ.ប.ន<br>-ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ | របាយការណ៍វឌ្ឍនភាព | x | x | x | x | x | x | x | x | x | x | x | x |
| | រៀបចំសិក្ខាសាលាផ្សព្វផ្សាយខ្លឹមសារនៃច្បាប់ស្ដីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន | | | របាយការណ៍សិក្ខាសាលា | x | | | | x | | | | x | | | |
| | បង្កើតយន្តការភាពជាដៃគូរដ្ឋ-ឯកជន តាមរយៈការបង្កើតក្រុមការងារចម្រុះពីវិស័យរដ្ឋ និងវិស័យឯកជនក្នុងវិស័យឌីជីថល | | | របាយការណ៍វឌ្ឍនភាព | | x | | | | | | | | | | |
| | រៀបចំឱ្យមានវេទិកាភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP) ជាប្រចាំ ដើម្បីស្វែងរកអត្ថប្រយោជន៍រួមក្នុងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ | | | របាយការណ៍វឌ្ឍនភាព | | | x | x | x | x | x | x | x | x | x | x |

| ល.រ* | ទិសដៅគោលនយោបាយ / វិធានការគោលនយោបាយគន្លឹះ | ល.ស** | ក្រសួង-ស្ថាប័ន | សូចនាករសមិទ្ធកម្មគន្លឹះ | ២០២៣ | | | | ២០២៤ | | | | ២០២៥ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| | ផ្សព្វផ្សាយអំពីមូលនិធិនៃការកសាងសមត្ថភាព និងស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន (CBRD) និង មូលនិធិកាតព្វកិច្ចសកលទូរគមនាគមន៍ (USO) ក្នុងការជំរុញការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ | | | របាយការណ៍វឌ្ឍនភាព | x | x | x | x | x | x | x | x | x | x | x | x |
| | **ខ. ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ និង ប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល** ផ្តោតលើ ៖ (១). ការកសាងហេដ្ឋារចនាសម្ព័ន្ធដែលគាំទ្រដល់ការធ្វើបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ ជាពិសេសការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ និង (២). ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល ដែលធានាបាននូវវិសាលភាពគ្របដណ្តប់ទាំងវិស័យធនាគារ និង វិស័យហិរញ្ញវត្ថុមិនមែនធនាគារ, លក្ខណៈអន្តរប្រតិបត្តិការ (Interoperability) ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ, ទំនុកចិត្ត និង ភាពជឿជាក់, និង ប្រសិទ្ធភាព និង សុវត្ថិភាពខ្ពស់ ដោយប្រើប្រាស់ និង បង្កើតលទ្ធភាពទាញយកអត្ថប្រយោជន៍ពីបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលកំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័ស ។ | | | | | | | | | | | | | | | |
| ៤ | អនុម័តក្របខណ្ឌអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីនៃការទូទាត់សងប្រាក់ឌីជីថលដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ | ១២ | -ធនាគារជាតិនៃកម្ពុជា<br>-ក.ស.ហ.វ<br>-អ.ស.ហ | របាយការណ៍វឌ្ឍនភាព | x | x | x | x | | | | | | | | |
| | រៀបចំសិក្ខាសាលាផ្សព្វផ្សាយ | | | របាយការណ៍វឌ្ឍនភាព | | | | x | | | | | | | | |
| ៥ | កសាងផែនការមេសម្រាប់ការកសាងហេដ្ឋារចនាសម្ព័ន្ធច្រកចេញ-ចូលប្រព័ន្ធទូទាត់សងប្រាក់ (Payment Gateway) ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និង អន្តរប្រតិបត្តិការ ដែលមានវិសាលភាពទូលំទូលាយគ្របដណ្តប់លើការទូទាត់សងប្រាក់ឌីជីថលលើវិស័យសាធារណៈ | ១៣ | -ក.ស.ហ.វ<br>-ធនាគារជាតិនៃកម្ពុជា<br>-អ.ស.ហ.<br>-ក.ប.ទ | របាយការណ៍វឌ្ឍនភាព | x | x | x | x | x | x | x | x | x | x | x | x |
| | ស្រាវជ្រាវអំពីឧត្តមានុវត្តន៍ក្នុងការរៀបចំកសាងហេដ្ឋារចនាសម្ព័ន្ធច្រកចេញ-ចូលប្រព័ន្ធទូទាត់សងប្រាក់ថ្នាក់ជាតិ (National Payment Gateway) | | | ឯកសារស្រាវជ្រាវ | | x | x | | | | | | | | | |
| | រៀបចំសេចក្តីព្រាងបឋមផែនការមេ | | | សេចក្តីព្រាងបឋម | | | | x | x | | | | | | | |

| ល.រ* | ទិសដៅគោលនយោបាយ / វិធានការគោលនយោបាយគន្លឹះ | ល.ស** | ក្រសួង-ស្ថាប័ន | សូចនាករ សមិទ្ធកម្មគន្លឹះ | ២០២៣ | | | | ២០២៤ | | | | ២០២៥ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| | រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាអន្តរក្រសួង និងកែសម្រួលលើសេចក្តី-ព្រាងផែនការមេ | | | របាយការណ៍កិច្ចប្រជុំ | | | | | | x | | | | | | |
| | រៀបចំសេចក្តីព្រាងចុងក្រោយ ជូនគណៈកម្មាធិការ ពិនិត្យ និងសម្រេច | | | សេចក្តីព្រាងបញ្ចប់ | | | | | | | x | x | | | | |
| | រៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងប្រកាសដាក់ឱ្យអនុវត្តដោយមានការចូលរួមពីក្រសួង-ស្ថាប័ន និងវិស័យឯកជន | | | របាយការណ៍សិក្ខាសាលា | | | | | | | | | x | x | x | x |
| ៦ | អភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល ប្រកបដោយបរិយាបន្នកម្ម ដោយធានាបាននូវភាពដែលអាចរកបាន (Availability), ថ្លៃសមរម្យ (Affordability), ភាពងាយស្រួល (Convenience) និងគុណភាព (Quality) ក៏ដូចជាធានាបាននូវដំណើរការ និងប្រសិទ្ធភាពនៃអន្តរប្រតិបត្តិការនៃផលិតផល សេវា ថ្នាល និងបណ្តាញទាក់ទងឌីជីថលនៅក្នុងវិស័យហិរញ្ញវត្ថុ | ១៤ | -ធនាគារជាតិ នៃកម្ពុជា<br>-ក.ស.ហ.វ<br>-អ.ស.ហ. | របាយការណ៍វឌ្ឍនភាព | x | x | x | x | x | x | x | x | | | | |
| | រៀបចំ ឬ កែសម្រួលស្តង់ដាអន្តរប្រតិបត្តិការសម្រាប់ប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលក្នុងស្រុក | | | របាយការណ៍វឌ្ឍនភាព | | | | | x | x | x | x | | | | |
| ៧ | រៀបចំ និង ដាក់ចេញនូវក្របខណ្ឌជំរុញ លើកទឹកចិត្ត និង ទាក់ទាញវិនិយោគ និង ការចូលរួមរបស់វិស័យឯកជនក្នុងការអភិវឌ្ឍហេដ្ឋារចនា-សម្ព័ន្ធពាក់ព័ន្ធនឹងហិរញ្ញវត្ថុ ជាពិសេស ច្រកចេញ-ចូលទូទាត់សងប្រាក់ឌីជីថល (Digital Payment Gateways) និង ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល និង បច្ចេកវិទ្យាហិរញ្ញវត្ថុ សំដៅជំរុញ និង អភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុឌីជីថល | ១៧ | -ធនាគារជាតិ នៃកម្ពុជា<br>-អ.ស.ហ.<br>-ក.ប.ទ | -របាយការណ៍វឌ្ឍនភាព | x | x | x | x | x | x | x | x | | | | |
| | បង្កើតក្រុមការងារអន្តរក្រសួងទទួលបន្ទុករៀបចំក្របខណ្ឌ | | | ឯកសារបង្កើតក្រុមការងារ | x | | | | | | | | | | | |

| ល.រ* | ទិសដៅគោលនយោបាយ / វិធានការគោលនយោបាយគន្លឹះ | ល.ស** | ក្រសួង-ស្ថាប័ន | សូចនាករ សមិទ្ធកម្មគន្លឹះ | ២០២៣ | | | | ២០២៤ | | | | ២០២៥ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| | ស្រាវជ្រាវ និងរៀបចំសេចក្តីព្រាងក្របខណ្ឌ | | | ឯកសារក្របខណ្ឌ | | x | x | | | | | | | | | |
| | រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាអន្តរក្រសួង និងកែសម្រួលលើសេចក្តី-ព្រាងក្របខណ្ឌ | | | របាយការណ៍កិច្ចប្រជុំ | | | | x | | | | | | | | |
| | រៀបចំសេចក្តីព្រាងចុងក្រោយ ជូនគណៈកម្មាធិការ ពិនិត្យ និងសម្រេច | | | សេចក្តីព្រាងបញ្ចប់ | | | | | x | x | | | | | | |
| | រៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងប្រកាសដាក់ឱ្យអនុវត្ត ដោយមានការចូលរួមពីក្រសួង-ស្ថាប័ន និងវិស័យឯកជន | | | របាយការណ៍សិក្ខាសាលា | | | | | | | x | x | | | | |
| ៨ | ធ្វើវិសោធនកម្ម ឬ កែសម្រួលច្បាប់ និង លិខិតបទដ្ឋានគតិយុត្តមួយចំនួននៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដោយកាត់បន្ថយនូវភាពមិនច្បាស់លាស់ ភាពចន្លោះប្រហោង និង ភាពខ្វះខាតរបស់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលអាចរាំងស្ទះដល់នវានុវត្តន៍នៃបច្ចេកវិទ្យាហិរញ្ញវត្ថុនៅក្នុងទីផ្សារ | ១៨ | -ក.ស.ហ.វ<br>-ធនាគារជាតិ នៃកម្ពុជា<br>-អ.ស.ហ.<br>-ក.ប.ទ | -ច្បាប់<br>-លិខិតបទដ្ឋានគតិយុត្ត | | | x | x | x | x | x | x | x | x | x | x |
| | រៀបចំឱ្យមានក្រុមអ្នកជំនាញសិក្សាលើចន្លោះប្រហោងផ្នែកច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត នៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ | | | របាយការណ៍វឌ្ឍភាព | x | x | x | x | | | | | | | | |
| | រៀបចំកិច្ចពិភាក្សាជាសាធារណៈជាមួយគ្រប់ភាគីពាក់ព័ន្ធ លើលទ្ធភាពក្នុងការកែសម្រួលច្បាប់ និង លិខិតបទដ្ឋានគតិយុត្តមួយចំនួន | | | របាយការណ៍កិច្ចពិភាក្សា | | | x | x | | | | | | | | |
| | សិក្សាសមិទ្ធិលទ្ធភាពក្នុងការរៀបចំច្បាប់ និងបទដ្ឋានគតិយុត្ត (ថ្មី) ពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ ពិសេសបទដ្ឋានគតិយុត្តពាក់ព័ន្ធបច្ចេកវិទ្យាមិនមែនធនាគារ | | | ឯកសារច្បាប់ / បទដ្ឋានគតិយុត្ត | | | | | x | x | x | x | x | x | x | x |

| ល.រ* | ទិសដៅគោលនយោបាយ / វិធានការគោលនយោបាយគន្លឹះ | ល.ស** | ក្រសួង-ស្ថាប័ន | សូចនាករសមិទ្ធកម្មគន្លឹះ | ២០២៣ | | | | ២០២៤ | | | | ២០២៥ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ៩ | រៀបចំយុទ្ធសាស្ត្រជាផែនទីចង្កុលផ្លូវសម្រាប់ការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ | ១៩ | -ក.ស.ហ.វ<br>-ធនាគារជាតិនៃកម្ពុជា<br>-អ.ស.ហ.<br>-ក្រ.ផែនការ<br>-ក.ប.ទ<br>-ក្រ.ឌ.វ.ប.ន<br>-ក.អ.យ.ក | ឯកសារផែនទីចង្កុលផ្លូវ | | | x | x | x | x | x | x | | | | |
| | បង្កើតក្រុមការងារអន្តរក្រសួងទទួលបន្ទុករៀបចំផែនទីចង្កុលផ្លូវ | | | ឯកសារបង្កើតក្រុមការងារ | x | | | | | | | | | | | |
| | រៀបចំសេចក្តីព្រាងបឋមនៃផែនទីចង្កុលផ្លូវ | | | សេចក្តីព្រាងយុទ្ធសាស្ត្រ | x | x | | | | | | | | | | |
| | រៀបចំកិច្ចប្រជុំពិគ្រោះយោបល់អន្តរក្រសួង និងកែសម្រួលលើសេចក្តី-ព្រាងផែនទីចង្កុលផ្លូវ | | | របាយការណ៍កិច្ចប្រជុំ | | | x | x | | | | | | | | |
| | រៀបចំសេចក្តីព្រាងចុងក្រោយ ជូនគណៈកម្មាធិការដើម្បីពិនិត្យ និងសម្រេច | | | សេចក្តីព្រាងបញ្ចប់ | | | | | x | | | | | | | |
| | រៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងប្រកាសដាក់ឱ្យអនុវត្តដោយមានការចូលរួមពីក្រសួង-ស្ថាប័ន និងវិស័យឯកជន | | | របាយការណ៍សិក្ខាសាលា | | | | | | x | | | | | | |
| | រៀបចំបញ្ចប់សេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា | | | ឯកសារគោលនយោបាយត្រូវបានដាក់ចេញ | x | x | x | x | | | | | | | | |
| ១០ | រៀបចំផែនការមេកសាងសមត្ថភាព និង ជំនាញផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុ | ២០ | -ក.អ.យ.ក<br>-ក.ស.ហ.វ | ឯកសារផែនការមេ | x | x | x | x | x | x | x | x | | | | |

| ល.រ* | ទិសដៅគោលនយោបាយ / វិធានការគោលនយោបាយគន្លឹះ | ល.ស** | ក្រសួង-ស្ថាប័ន | សូចនាករ សមិទ្ធកម្មគន្លឹះ | ២០២៣ | | | | ២០២៤ | | | | ២០២៥ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| | | | -ធនាគារជាតិ នៃកម្ពុជា<br>-អ.ស.ហ.<br>-ក្រ.ផែនការ<br>-ក.ប.ទ<br>-ក្រ.ឧ.វ.ប.ន | | | | | | | | | | | | | |
| | បង្កើតក្រុមការងារអន្តរក្រសួងទទួលបន្ទុករៀបចំផែនការមេ | | | ឯកសារស្រាវជ្រាវ | x | | | | | | | | | | | |
| | រៀបចំសេចក្តីព្រាងបឋមនៃផែនការមេ | | | សេចក្តីព្រាងបឋម | | x | x | x | | | | | | | | |
| | រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាអន្តរក្រសួង និងកែសម្រួលលើសេចក្តី-ព្រាងផែនការមេ | | | របាយការណ៍កិច្ចប្រជុំ | | | | | x | x | | | | | | |
| | រៀបចំសេចក្តីព្រាងចុងក្រោយ ជូនគណៈកម្មាធិការពិនិត្យ និងសម្រេច | | | សេចក្តីព្រាងបញ្ចប់ | | | | | | | x | | | | | |
| | រៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងប្រកាសដាក់ឱ្យអនុវត្តដោយមានការចូលរួមពីក្រសួង-ស្ថាប័ន និងវិស័យឯកជន | | | របាយការណ៍សិក្ខាសាលា | | | | | | | | x | | | | |

| ល.រ* | ទិសដៅគោលនយោបាយ / វិធានការគោលនយោបាយគន្លឹះ | ល.ស** | ក្រសួង-ស្ថាប័ន | សូចនាករ សមិទ្ធកម្មគន្លឹះ | ២០២៣ | | | | ២០២៤ | | | | ២០២៥ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ១១ | បង្កើតយន្តការស្ថាប័នដែលអំណោយផលដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងទីផ្សារតាមរយៈ ៖ (១). ការបង្កើតឱ្យមានមជ្ឈមណ្ឌលបច្ចេក-វិទ្យាហិរញ្ញវត្ថុសម្រាប់វិស័យហិរញ្ញវត្ថុមិនមែនធនាគារ, (២). ការបង្កើតឱ្យមានយន្តការសម្របសម្រួល និង កិច្ចសហការផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុរវាងនិយ័តករនៅក្នុងវិស័យធនាគារ និង និយ័តករនៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ, និង (៣). ការបង្កើតឱ្យមានបរិស្ថានសាកល្បងបច្ចេក-វិទ្យាហិរញ្ញវត្ថុ (Regulatory Sandboxes) បើមានភាពចាំបាច់នៅក្នុងទីផ្សារ | ២១ | -ក.ស.ហ.វ<br>-ធនាគារជាតិនៃកម្ពុជា<br>-អ.ស.ហ.<br>-ក.ប.ទ | -របាយការណ៍វឌ្ឍនភាព<br>-មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ | x | x | x | x | x | x | x | x | | | | |
| | បង្កើតយន្តការសំខាន់ៗក្នុងការសម្របសម្រួល និងបង្កើនកិច្ចសហការផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុរវាងនិយ័តករនៅក្នុងវិស័យធនាគារ និង និយ័តករនៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ | | | ឯកសារយន្តការ | | | | | x | x | x | x | | | | |
| | បង្កើតបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុមិនមែនធនាគាររួមក្រោមអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | | | របាយការណ៍វឌ្ឍនភាព | | x | x | x | x | x | x | x | | | | |
| ១២ | លើកកម្ពស់ចំណេះដឹងរបស់សាធារណជន និង សហគ្រិន ប្រកបដោយបរិយាបន្នកម្ម អំពីការប្រើប្រាស់ឧបករណ៍ទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកជំនួសឱ្យសាច់ប្រាក់ សំដៅផ្លាស់ប្តូរឥរិយាបថ ទំនុកចិត្ត និង ភាពជឿជាក់លើមធ្យោបាយទូទាត់សងប្រាក់ឌីជីថល | ២២ | -ធនាគារជាតិនៃកម្ពុជា<br>-អ.ស.ហ.<br>-ក.ស.ហ.វ<br>-ក.ប.ទ<br>-ក្រ.ឧ.វ.ប.ន<br>-ក្រសួង-ស្ថាប័នពាក់ព័ន្ធ | របាយការណ៍វឌ្ឍនភាព | x | x | x | x | x | x | x | x | x | x | x | x |

| ល.រ* | ទិសដៅគោលនយោបាយ / វិធានការគោលនយោបាយគន្លឹះ | ល.ស** | ក្រសួង-ស្ថាប័ន | សូចនាករសមិទ្ធកម្មគន្លឹះ | ២០២៣ | | | | ២០២៤ | | | | ២០២៥ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| | បង្កើតមាតិកាថ្មីៗ (ចំណេះដឹង និងអត្ថប្រយោជន៍) ជាប្រចាំ ដើម្បីផ្សព្វផ្សាយដល់សាធារណជន និង សហគ្រិនតាមរយៈបណ្តាញសង្គមនានា | | | របាយការណ៍វឌ្ឍនភាព | x | x | x | x | x | x | x | x | x | x | x | x |
| | រៀបចំកម្មវិធីសិក្សាអក្ខរកម្មឌីជីថលអំពីការប្រើប្រាស់ឧបករណ៍ទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក | | | ឯកសារកម្មវិធីសិក្សា | | x | x | | | | | | | | | |
| | រៀបចំវគ្គបណ្តុះបណ្តាលរយៈពេលខ្លីជាប្រចាំ តាមរយៈអនឡាញ និងដោយផ្ទាល់ | | | របាយការណ៍បណ្តុះបណ្តាល | x | x | x | x | x | x | x | x | x | x | x | x |
| | រៀបចំសិក្ខាសាលាផ្សព្វផ្សាយចំណេះដឹង និងក្របខណ្ឌច្បាប់ពាក់ព័ន្ធដល់សាធារណជន និងសហគ្រិន | | | របាយការណ៍សិក្ខាសាលា | | | | x | | | | x | | | | x |
| | **គ.ឡូហ្ស៊ីស្ទិក និង ការដឹកជញ្ជូនគោលដៅចុងក្រោយ** ផ្តោតលើ ៖ ការកែលម្អ និង ការពង្រឹងប្រព័ន្ធឡូហ្ស៊ីស្ទិក និង ការដឹកជញ្ជូនគោលដៅចុងក្រោយឱ្យមានប្រសិទ្ធភាពខ្ពស់ និងវិសាលភាពធំ ។ | | | | | | | | | | | | | | | |
| ១៣ | កសាងយុទ្ធសាស្ត្រអភិវឌ្ឍមូលធនមនុស្សក្នុងវិស័យឡូហ្ស៊ីស្ទិក ដើម្បីគាំទ្រដល់ការអភិវឌ្ឍនៃវិស័យនេះ ក្នុងដំណាក់កាលបន្ទាប់ | ២៨ | -ក្រ.ស.ដ<br>-ក.អ.យ.ក<br>-ក្រ.ការងារ<br>-ក.ស.ហ.វ<br>-ក.ប.ទ<br>-ក្រ.ឱ.វ.ប.ន | ឯកសារយុទ្ធសាស្ត្រ | x | x | x | x | | | | | | | | |
| | បង្កើតក្រុមការងារអន្តរក្រសួងទទួលបន្ទុករៀបចំយុទ្ធសាស្ត្រ | | | ឯកសារបង្កើតក្រុមការងារ | x | | | | | | | | | | | |
| | រៀបចំសេចក្តីព្រាងបឋមនៃយុទ្ធសាស្ត្រ | | | សេចក្តីព្រាងបឋម | x | x | | | | | | | | | | |

| ល.រ* | ទិសដៅគោលនយោបាយ / វិធានការគោលនយោបាយគន្លឹះ | ល.ស** | ក្រសួង-ស្ថាប័ន | សូចនាករ សមិទ្ធកម្មគន្លឹះ | ២០២៣ | | | | ២០២៤ | | | | ២០២៥ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| | រៀបចំកិច្ចប្រជុំពិគ្រោះយោបល់អន្តរក្រសួង និងកែសម្រួលសេចក្តីព្រាង | | | របាយការណ៍កិច្ចប្រជុំ | | x | | | | | | | | | | |
| | រៀបចំសេចក្តីព្រាងចុងក្រោយ ជូនគណៈកម្មាធិការពិនិត្យ និងសម្រេច | | | សេចក្តីព្រាងបញ្ចប់ | | x | x | | | | | | | | | |
| | រៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងប្រកាសដាក់ឱ្យអនុវត្តដោយមានការចូលរួមពីក្រសួង-ស្ថាប័ន និងវិស័យឯកជន | | | របាយការណ៍សិក្ខាសាលា | | | x | x | | | | | | | | |
| ១៤ | រៀបចំកសាងផែនការយុទ្ធសាស្ត្រជំរុញ និងអភិវឌ្ឍវិស័យដឹកជញ្ជូនគោលដៅចុងក្រោយ ក្នុងន័យបង្កើតប្រព័ន្ធអេកូឡូស៊ី និងយន្តការដែលជាក់លាក់ ក្នុងវិស័យនេះ ដោយឈរលើគោលការណ៍ប្រសិទ្ធភាព, នវានុវត្តន៍, ចីរភាពបរិស្ថាន, ភាពធន់នឹងវិបត្តិ និងអន្តរទំនាក់ទំនង | ៣០ | -ក្រ.ស.ជ<br>-ក.ប.ទ<br>-ក្រ.ផែនការ<br>-ក.ស.ហ.វ<br>-ក្រ.ឧ.វ.ប.ន | ឯកសារផែនការ | x | x | x | x | x | x | | | | | | |
| | បង្កើតក្រុមការងារអន្តរក្រសួងទទួលបន្ទុករៀបចំយុទ្ធសាស្ត្រ | | | ឯកសារបង្កើតក្រុមការងារ | x | | | | | | | | | | | |
| | រៀបចំសេចក្តីព្រាងបឋមផែនការយុទ្ធសាស្ត្រ | | | សេចក្តីព្រាងបឋម | x | x | | | | | | | | | | |
| | រៀបចំកិច្ចប្រជុំពិគ្រោះយោបល់អន្តរក្រសួង និងកែសម្រួលសេចក្តីព្រាង | | | របាយការណ៍កិច្ចប្រជុំ | | x | x | | | | | | | | | |
| | រៀបចំសេចក្តីព្រាងចុងក្រោយជូនគណៈកម្មាធិការពិនិត្យ និងសម្រេច | | | សេចក្តីព្រាងបញ្ចប់ | | | x | x | | | | | | | | |
| | រៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងប្រកាសដាក់ឱ្យអនុវត្ត ដោយមានការចូលរួមពីក្រសួង-ស្ថាប័ន និងវិស័យឯកជន | | | របាយការណ៍សិក្ខាសាលា | | | | | x | x | | | | | | |

| ល.រ* | ទិសដៅគោលនយោបាយ / វិធានការគោលនយោបាយគន្លឹះ | ល.ស** | ក្រសួង-ស្ថាប័ន | សូចនាករ សមិទ្ធកម្មគន្លឹះ | ២០២៣ | | | | ២០២៤ | | | | ២០២៥ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ១៥ | ធ្វើវិសោធនកម្ម ឬ កែសម្រួលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការដឹកជញ្ជូនការចែកចាយបញ្ញើ និងភស្តុភារកម្មប្រៃសណីយ៍នៅក្នុងស្រុក ក្នុងន័យធ្វើសេរីភាវូបនីយកម្មលើសេវានេះ | ៣៣ | -ក្រ.ស.ជ<br>-ក.ប.ទ<br>-ក.ស.ហ.វ | ឯកសារច្បាប់/ លិខិតបទដ្ឋានគតិយុត្ត | x | x | x | x | x | x | x | x | x | x | x | x |
| | រៀបចំក្រុមអ្នកជំនាញ ធ្វើការសិក្សាលើចន្លោះប្រហោងផ្នែកច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងការដឹកជញ្ជូនការចែកចាយបញ្ញើ និងភស្តុភារកម្មប្រៃសណីយ៍នៅក្នុងស្រុក | | | របាយការណ៍វឌ្ឍភាព | x | x | x | x | x | x | | | | | | |
| | រៀបចំកិច្ចពិភាក្សាជាសាធារណៈជាមួយភាគីពាក់ព័ន្ធ លើការកែសម្រួលច្បាប់ និង លិខិតបទដ្ឋានគតិយុត្តមួយចំនួន | | | របាយការណ៍កិច្ចពិភាក្សា | | | | | | | x | x | | | | |
| | ពិនិត្យលទ្ធភាពក្នុងការកែសម្រួលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធមួយចំនួន | | | របាយការណ៍វឌ្ឍភាព | | | | | | | x | x | x | x | x | x |
| | **II. ការកសាងទំនុកចិត្ត និងភាពជឿជាក់លើប្រព័ន្ធឌីជីថល ៖ ការរៀបចំក្របខណ្ឌច្បាប់ និងការពង្រឹងការគ្រប់គ្រងសន្តិសុខសាយប័រ** | | | | | | | | | | | | | | | |
| ចំណាំ ៖ វិធានការគោលនយោបាយនៅក្នុងផ្នែកទី ២ នេះ ស្ថិតក្រោមការសម្របសម្រួលរបស់ **គណៈកម្មាធិការសន្តិសុខឌីជីថល** ដែលនៅក្រៅវិសាលភាពនៃការអនុវត្តផែនការសកម្មភាព ៣ ឆ្នាំរំកិល ២០២៣-២០២៥ របស់ គ.ស.ធ.ឌ. ។ ក្នុងន័យនេះ, វិធានការគោលនយោបាយនៅក្នុងផ្នែកនេះនឹងមិនត្រូវបានគូសរំលេច ។ | | | | | | | | | | | | | | | | |
| [--] | | | | | | | | | | | | | | | | |
| | **III. ការកសាងពលរដ្ឋឌីជីថល ៖ ភាពជាអ្នកដឹកនាំឌីជីថល, បណ្តុំធនធានមនុស្សដែលមានទេពកោសល្យឌីជីថល, និង ពលរដ្ឋឌីជីថល ទាំងនៅក្នុងវិស័យសាធារណៈ និង វិស័យឯកជន និងជ្រៀតដល់កម្រិតសហគមន៍មូលដ្ឋាន** | | | | | | | | | | | | | | | |
| | **ក. អ្នកដឹកនាំឌីជីថល** ផ្តោតលើ ៖ ការអភិវឌ្ឍធនធានមនុស្សកម្ពុជាក្លាយជាអ្នកដឹកនាំឌីជីថលតម្រូវឱ្យមានការយកចិត្តទុកដាក់លើការអភិវឌ្ឍសមត្ថភាពទាំងនៅក្នុងវិស័យសាធារណៈ និងវិស័យឯកជនដោយក្នុងនោះ ការអភិវឌ្ឍសមត្ថភាពនៃអ្នកដឹកនាំឌីជីថលនៅក្នុងវិស័យសាធារណៈ នឹងជាអាទិភាពចម្បង សម្រាប់ការបង្កើតរដ្ឋាភិបាលឌីជីថល ។ | | | | | | | | | | | | | | | |

| ល.រ* | ទិសដៅគោលនយោបាយ / វិធានការគោលនយោបាយគន្លឹះ | ល.ស** | ក្រសួង-ស្ថាប័ន | សូចនាករសមិទ្ធកម្មគន្លឹះ | ២០២៣ | | | | ២០២៤ | | | | ២០២៥ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ១៦ | រៀបចំផែនការរយៈពេលខ្លី និង មធ្យម សម្រាប់ការជំរុញការចាប់យក និង ការប្រើប្រាស់ឌីជីថលក្នុងការគ្រប់គ្រង និង ការចាត់ចែងការងារ ព្រមទាំង ការលើកកម្ពស់ការបណ្តុះបណ្តាលជំនាញឌីជីថល និង ភាពជាអ្នកដឹកនាំឌីជីថល នៅក្នុងវិស័យឯកជន | ៤៩ | -ក.ស.ហ.វ<br>-ក.អ.យ.ក<br>-ក្រ.ការងារ<br>-ក.ប.ទ<br>-ក្រ.ឧ.វ.ប.ន<br>-ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ | ឯកសារផែនការ | | | x | x | x | x | x | x | | | | |
| | បង្កើតក្រុមការងារអន្តរក្រសួងទទួលបន្ទុករៀបចំផែនការ | | | ឯកសារបង្កើតក្រុមការងារ | | | x | | | | | | | | | |
| | ធ្វើសេចក្តីព្រាងបឋមនៃផែនការ | | | សេចក្តីព្រាងបឋម | | | x | x | | | | | | | | |
| | រៀបចំកិច្ចប្រជុំពិគ្រោះយោបល់អន្តរក្រសួង និងកែសម្រួលសេចក្តីព្រាង | | | របាយការណ៍កិច្ចប្រជុំ | | | | | x | | | | | | | |
| | រៀបចំសេចក្តីព្រាងចុងក្រោយ ជូនគណៈកម្មាធិការពិនិត្យ និងសម្រេច | | | សេចក្តីព្រាងបញ្ចប់ | | | | | | x | x | | | | | |
| | រៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងប្រកាសដាក់ឱ្យអនុវត្ត ដោយមានការចូលរួមពីក្រសួង-ស្ថាប័ន និងវិស័យឯកជន | | | របាយការណ៍សិក្ខាសាលា | | | | | | | | x | | | | |
| ១៧ | បង្កើនការផ្ទេរធនធាន និង កៀរគរការគាំទ្រទាំងផ្នែកបច្ចេកទេស និង ថវិកា ក៏ដូចជាកិច្ចសហប្រតិបត្តិការនានា ពីសំណាក់ដៃគូអភិវឌ្ឍន៍ និង វិស័យឯកជនសម្រាប់ការអភិវឌ្ឍធនធានមនុស្សឌីជីថលនៅថ្នាក់ក្រោមជាតិ | ៥០ | -ក.ស.ហ.វ<br>-ក្រ.មហាផ្ទៃ<br>-ក.ប.ទ<br>-ក្រ.មុខងារ សាធារណៈ<br>-ក្រ.ឧ.វ.ប.ន | របាយការណ៍វឌ្ឍនភាព | x | x | x | x | x | x | x | x | x | x | x | x |

| ល.រ* | ទិសដៅគោលនយោបាយ / វិធានការគោលនយោបាយគន្លឹះ | ល.ស** | ក្រសួង-ស្ថាប័ន | សូចនាករ សមិទ្ធកម្មគន្លឹះ | ២០២៣ | | | | ២០២៤ | | | | ២០២៥ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| | ដាក់ចេញយុទ្ធនាការថ្នាក់ជាតិ កៀរគរការគាំទ្រការអភិវឌ្ឍធនធានមនុស្សឌីជីថលនៅថ្នាក់ក្រោមជាតិ | | | ឯកសារយុទ្ធនាការ | x | x | | | | | | | | | | |
| | បង្កើនកិច្ចសហការរវាងរដ្ឋ-ឯកជន និងដៃគូអភិវឌ្ឍន៍ តាមរយៈការបង្កើតកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សឌីជីថល | | | ឯកសារកម្មវិធី | | | x | x | | | | | | | | |
| | ជំរុញ និងពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន និងបច្ចេកវិទ្យាក្នុងការអភិវឌ្ឍធនធានមនុស្សឌីជីថលនៅថ្នាក់ក្រោមជាតិ | | | របាយការណ៍វឌ្ឍនភាព | | | | | x | x | x | x | x | x | x | x |
| | ផ្សព្វផ្សាយពីលទ្ធផលនៃកម្មវិធីអភិវឌ្ឍធនធានមនុស្សឌីជីថលទៅកាន់សាធារណជន វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ | | | របាយការណ៍វឌ្ឍនភាព | | | | | | | | | x | x | x | x |
| | **ខ. បណ្តុំមនុស្សដែលមានទេពកោសល្យឌីជីថល** ផ្តោតលើ ៖ ការប្រមូលផ្តុំ និង ការកសាងបណ្តុំធនធានមនុស្សដែលមានទេពកោសល្យឌីជីថល ។ | | | | | | | | | | | | | | | |
| ១៨ | បង្កើត និង ធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យគ្រប់គ្រងថ្នាក់ជាតិស្តីពីតម្រូវការ និង ការផ្គត់ផ្គង់កម្លាំងពលកម្មជំនាញឌីជីថល ដោយធ្វើការសិក្សាជាទៀងទាត់ដើម្បីកំណត់ឱ្យបានជាក់លាក់អំពីបរិមាណ និង ប្រភេទជំនាញឌីជីថលដែលមានតម្រូវការនៅក្នុងទីផ្សារបច្ចុប្បន្ន និង ពេលអនាគត | ៥១ | -ក្រ.ការងារ<br>-ក.អ.យ.ក<br>-ក្រ.ឧ.វ.ប.ន<br>-ក.ប.ទ<br>-ក.ស.ហ.វ | -ទិន្នន័យជំនាញឌីជីថល<br>-ប្រព័ន្ធទិន្នន័យគ្រប់គ្រងកម្លាំងពលកម្មថ្នាក់ជាតិ | x | x | x | x | x | x | x | x | x | x | x | x |
| | បង្កើតក្រុមការងារអន្តរក្រសួងទទួលបន្ទុក | | | ឯកសារបង្កើតក្រុមការងារ | x | | | | | | | | | | | |
| | សិក្សា និងប្រមូលទិន្នន័យអំពីតម្រូវការ និងការផ្គត់ផ្គង់ជំនាញឌីជីថលក្នុងទីផ្សារ | | | ឯកសារស្រាវជ្រាវ | | x | x | | x | | | | x | | | |
| | រៀបចំទស្សនាទាន និងអភិវឌ្ឍប្រព័ន្ធទិន្នន័យគ្រប់គ្រងថ្នាក់ជាតិ | | | ប្រព័ន្ធទិន្នន័យ | | x | x | x | x | x | | | | | | |

| ល.រ* | ទិសដៅគោលនយោបាយ / វិធានការគោលនយោបាយគន្លឹះ | ល.ស** | ក្រសួង-ស្ថាប័ន | សូចនាករសមិទ្ធកម្មគន្លឹះ | ២០២៣ | | | | ២០២៤ | | | | ២០២៥ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| | អនុវត្ត និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យគ្រប់គ្រងថ្នាក់ជាតិ ស្ដីពីតម្រូវការជំនាញឌីជីថល | | | របាយការណ៍វឌ្ឍនភាព | | | | | | | x | x | x | x | x | x |
| | រៀបចំសិក្ខាសាលាផ្សព្វផ្សាយ ដល់ក្រសួង-ស្ថាប័ន វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធ | | | របាយការណ៍សិក្ខាសាលា | | | | | | | x | x | x | x | x | x |
| ១៩ | រៀបចំ និង ធ្វើបច្ចុប្បន្នភាពជាទៀងទាត់នូវទេពកោសល្យជំនាញ និង ការបណ្ដុះគំនិតថ្មី ដោយផ្អែកលើតម្រូវការជំនាញថ្មី (New skills Requirement) នៅក្នុងវិស័យឯកជន | ៥៤ | -ក.អ.យ.ក<br>-ក្រ.ការងារ<br>-ក្រ.ឧ.វ.ប.ន<br>-ក.ស.ហ.វ<br>-ក.ប.ទ | របាយការណ៍វឌ្ឍនភាព | x | x | x | x | x | x | x | x | x | x | x | x |
| | សិក្សា និងប្រមូលទិន្នន័យនូវទេពកោសល្យជំនាញ និង ការបណ្ដុះគំនិតថ្មីក្នុងវិស័យអាទិភាពនានា | | | របាយការណ៍ស្រាវជ្រាវ | x | x | | x | | x | | x | | x | | x |
| | រៀបចំសិក្ខាសាលាផ្សព្វផ្សាយទេពកោសល្យជំនាញ និង ការបណ្ដុះគំនិតថ្មី ដល់សិស្ស-និស្សិត មន្ត្រីរាជការ បុគ្គលិកបំរើការងារក្នុងវិស័យឯកជន និងសាធារណជនទូទៅ | | | របាយការណ៍សិក្ខាសាលា | | | | x | | | | x | | | | x |
| | ជំរុញឱ្យមានកម្មវិធីទេពកោសល្យជំនាញឌីជីថលក្នុងវិស័យឯកជន និងវិស័យសាធារណៈ | | | របាយការណ៍វឌ្ឍនភាព | x | x | x | x | x | x | x | x | x | x | x | x |
| | **គ. ពលរដ្ឋឌីជីថល** ផ្ដោតលើ ៖ (១). ការលើកកម្ពស់គុណភាពនៃការសិក្សាកម្រិតទូទៅជារួម និង (២). ការបន្តធ្វើសមាហរណកម្មវិស័យបច្ចេកវិទ្យាឌីជីថល ទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិតនៃប្រព័ន្ធអប់រំ និង កម្រិតបណ្ដុះបណ្ដាលបច្ចេកទេស និង វិជ្ជាជីវៈ ដើម្បីធានាថា ប្រជាពលរដ្ឋមានចំណេះដឹង និង ជំនាញឌីជីថលគ្រប់គ្រាន់ ព្រមទាំងចេះប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ប្រកបដោយប្រសិទ្ធភាព និង ការទទួលខុសត្រូវខ្ពស់ ។ | | | | | | | | | | | | | | | |
| ២០ | រៀបចំផែនការផ្ដល់មគ្គុទេសក៍ជំនាញ និង អាជីពឌីជីថល នៅគ្រប់កម្រិតអប់រំ និង កម្រិតបណ្ដុះបណ្ដាល ព្រមទាំងបញ្ជ្រាបការយល់ដឹង និង ការ | ៦៤ | -ក្រ.ការងារ<br>-ក.អ.យ.ក | ឯកសារផែនការ | x | x | x | x | x | x | | | | | | |

| ល.រ* | ទិសដៅគោលនយោបាយ / វិធានការគោលនយោបាយគន្លឹះ | ល.ស** | ក្រសួង-ស្ថាប័ន | សូចនាករសមិទ្ធកម្មគន្លឹះ | ២០២៣ | | | | ២០២៤ | | | | ២០២៥ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| | បំពាក់បំប៉នចំណេះដឹង និង ជំនាញឌីជីថល សម្រាប់ការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ដើម្បីជំរុញការចាប់យកឌីជីថល ប្រកបដោយបរិយាបន្ន-កម្ម | | -ក្រ.ឧ.វ.ប.ន<br>-ក.ស.ហ.វ<br>-ក.ប.ទ | | | | | | | | | | | | | |
| | បង្កើតក្រុមការងារអន្តរក្រសួងទទួលបន្ទុករៀបចំផែនការ | | | ឯកសារបង្កើតក្រុមការងារ | x | | | | | | | | | | | |
| | រៀបចំសេចក្តីព្រាងបឋមនៃផែនការ | | | សេចក្តីព្រាងបឋម | x | x | | | | | | | | | | |
| | រៀបចំកិច្ចប្រជុំពិគ្រោះយោបល់អន្តរក្រសួង និងកែសម្រួលសេចក្តីព្រាង | | | របាយការណ៍កិច្ចប្រជុំ | | x | x | | | | | | | | | |
| | រៀបចំសេចក្តីព្រាងចុងក្រោយជូនគណៈកម្មាធិការពិនិត្យ និងសម្រេច | | | សេចក្តីព្រាងបញ្ចប់ | | | x | x | | | | | | | | |
| | រៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងប្រកាសដាក់ឱ្យអនុវត្ត ដោយមានការចូលរួមពីក្រសួង-ស្ថាប័ន និងវិស័យឯកជន | | | របាយការណ៍វឌ្ឍនភាព | | | | | x | x | | | | | | |
| ២១ | រៀបចំយន្តការផ្សព្វផ្សាយ រួមមានជាអាទិ៍ ការរៀបចំព្រឹត្តិការណ៍ជាតិ ឬ យុទ្ធនាការជាតិ ដើម្បីបង្កើនការយល់ដឹងអំពីអត្ថប្រយោជន៍នៃការចាប់យកឌីជីថល ដោយសហការជាមួយនឹងដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និង សហគមន៍មូលដ្ឋាន | ៦៥ | -ក្រសួង-ស្ថាប័នដែលជាសមាស-ភាព គ.ស.ធ.ឌ.<br>-ក្រសួង-ស្ថាប័នពាក់ព័ន្ធ | របាយការណ៍វឌ្ឍនភាព | x | x | x | x | x | x | x | x | x | x | x | x |
| | រៀបចំយន្តការផ្សព្វផ្សាយដែលរួមបញ្ចូលព្រឹត្តិការណ៍ជាតិ ឬ យុទ្ធនាការជាតិក្នុងការចាប់យកឌីជីថល | | | ឯកសារយន្តការ | x | | | | | | | | | | | |
| | សហការជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និង សហគមន៍មូល-ដ្ឋានបញ្ជ្រាបការយល់ដឹងអំពីចំណេះដឹងអក្ខរកម្មឌីជីថលកម្រិតមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃ ដល់សាធារណជនទូទៅ និងជំនាញឌីជីថលដល់បុគ្គលិកបំរើការងារក្នុងវិស័យអាទិភាព | | | របាយការណ៍វឌ្ឍនភាព | | x | x | x | | | | | | | | |

| ល.រ* | ទិសដៅគោលនយោបាយ / វិធានការគោលនយោបាយគន្លឹះ | ល.ស** | ក្រសួង-ស្ថាប័ន | សូចនាករសមិទ្ធកម្មគន្លឹះ | ២០២៣ | | | | ២០២៤ | | | | ២០២៥ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| | រៀបចំសិក្ខាសាលាតម្រង់ទិសអំពីជំនាញ និង អាជីពការងារក្នុងវិស័យឌីជីថលដល់សិស្សានុសិស្សនៅតាមវិទ្យាល័យ | | | របាយការណ៍សិក្ខាសាលា | | | | | x | | x | | x | | x | |
| | រៀបចំមាតិកានានាផ្សព្វផ្សាយតាមបណ្តាញសង្គម | | | ឯកសារមាតិកា | x | x | x | x | x | x | x | x | x | x | x | x |
| | **IV. ការកសាងរដ្ឋាភិបាលឌីជីថល ៖ រដ្ឋាភិបាល និង សេវាសាធារណៈឌីជីថល តាមរយៈការបន្តផ្តល់ភាពជាម្ចាស់ និង ការទទួលខុសត្រូវនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង-ស្ថាប័នសំខាន់ៗ និងការកសាងស្តង់ដាបច្ចេកទេសរួមសម្រាប់ការអនុវត្តនៅតាមក្រសួង-ស្ថាប័ន, គន្លឹះជំរុញការអនុវត្តឌីជីថល និងអភិបាលកិច្ចឌីជីថលផ្អែកលើទិន្នន័យ** | | | | | | | | | | | | | | | |
| | **ក. គន្លឹះជំរុញការអនុវត្តឌីជីថល** ផ្តោតលើ ៖ (១). ការរៀបចំក្របខណ្ឌ និងផែនការច្បាស់លាស់ រួមទាំងធនធាន និង សមត្ថភាព និង (២). ការអភិវឌ្ឍថ្នាលបច្ចេកវិទ្យាជាមូលដ្ឋាននានា ដែលការណ៍នេះនឹងជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ស្ថាប័ននានា ដោយបំពេញមុខងារឱ្យគ្នាទៅវិញទៅមក និង មានសង្គតិភាពជាប្រព័ន្ធរួមរបស់រាជរដ្ឋាភិបាល សំដៅធានានូវប្រសិទ្ធភាព និង សុវត្ថិភាពរបស់ប្រព័ន្ធរដ្ឋាភិបាលឌីជីថល ទាំងមូល ។ | | | | | | | | | | | | | | | |
| ២២ | ជំរុញការប្រើប្រាស់អត្តសញ្ញាណឌីជីថល និង ហត្ថលេខាឌីជីថលក្នុងការកំណត់ និង ការផ្ទៀងផ្ទាត់អត្តសញ្ញាណឌីជីថល ឱ្យបានទូលំទូលាយចំពោះប្រជាពលរដ្ឋ ស្ថាប័នឯកជន និង ស្ថាប័នសាធារណៈ | ៨៤ | -ក.ស.ហ.វ<br>-ក.ប.ទ<br>-ក្រ.ឌ.វ.ប.ន | របាយការណ៍វឌ្ឍនភាព | | x | x | x | x | x | x | x | x | x | x | x |
| | រៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីអត្តសញ្ញាណឌីជីថល និង ហត្ថលេខាឌីជីថលដល់ស្ថាប័នពាក់ព័ន្ធទាំងរដ្ឋ និងឯកជន | | | របាយការណ៍សិក្ខាសាលា | | x | | x | | x | | x | | x | | x |
| | រៀបចំអនុវត្តយន្តការផ្សព្វផ្សាយឱ្យបានទូលំទូលាយតាមបណ្តាញសង្គមជូនដល់សាធារណជន | | | របាយការណ៍វឌ្ឍនភាព | | x | | x | | x | | x | | x | | x |
| | សហការជាមួយបណ្តាវិស័យឯកជននានាដើម្បីផ្សព្វផ្សាយពីអត្តសញ្ញាណឌីជីថល និងហត្ថលេខាឌីជីថល | | | របាយការណ៍វឌ្ឍនភាព | x | | x | | x | | x | | x | | x | |
| ២៣ | ធានាសមាហរណកម្មទិន្នន័យអ្នកប្រើប្រាស់ និង សហគ្រាសទាំងឡាយនៅក្នុងវិស័យឯកជន | ៨៨ | -ក.ស.ហ.វ<br>-ក.ប.ទ<br>-ក្រ.ឌ.វ.ប.ន | របាយការណ៍វឌ្ឍនភាព | x | x | x | x | x | x | x | x | x | x | x | x |

| ល.រ* | ទិសដៅគោលនយោបាយ / វិធានការគោលនយោបាយគន្លឹះ | ល.ស** | ក្រសួង-ស្ថាប័ន | សូចនាករសមិទ្ធកម្មគន្លឹះ | ២០២៣ | | | | ២០២៤ | | | | ២០២៥ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| | រៀបចំលិខិតបទដ្ឋានគតិយុត្តនានាគាំទ្រក្នុងការសម្រួលការធ្វើសមាហរណកម្មទិន្នន័យក្នុងវិស័យឯកជន | | | លិខិតបទដ្ឋានគតិយុត្ត | x | x | x | x | x | x | x | x | | | | |
| | រៀបចំយន្តការអន្តរប្រតិបត្តិការ ឬ ស្តង់ដាក្នុងការធ្វើការសមាហរណកម្មទិន្នន័យ | | | ឯកសារយន្តការ / ស្តង់ដា | x | x | x | x | x | x | x | x | | | | |
| | ជំរុញ និងផ្សព្វផ្សាយយន្តការនៃការធ្វើសមាហរណកម្មទិន្នន័យ | | | របាយការណ៍វឌ្ឍនភាព | | | | | x | x | x | x | x | x | x | x |
| | **V. ការជំរុញធុរកិច្ចឌីជីថល ៖ ការជំរុញបរិវត្តកម្មឌីជីថលសហគ្រាស, ការបង្កើតប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព និងធុរកិច្ចថ្មី, និងការលើកកម្ពស់ខ្សែច្រវាក់តម្លៃឌីជីថល** | | | | | | | | | | | | | | | |
| | **ក. បរិវត្តកម្មឌីជីថលសហគ្រាស** ផ្តោតលើ ៖ (១). ការធ្វើទំនើបកម្មរចនាសម្ព័ន្ធសហគ្រាស និង (២). ការលើកកម្ពស់ការត្រៀមខ្លួនរបស់សហគ្រាសនៅក្នុងស្រុកក្នុងការចាប់យក និង ការធ្វើសមាហរណកម្មខ្សែច្រវាក់ផលិតកម្មទៅក្នុងសេដ្ឋកិច្ចឌីជីថល នៅក្នុងប្រទេស តំបន់ និង សកល ។ | | | | | | | | | | | | | | | |
| ២៤ | បន្តជំរុញ និង លើកកម្ពស់ការអនុវត្តវិធានការអភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម ដែលមានចែងក្នុងគោលនយោបាយអភិវឌ្ឍន៍សហគ្រាសធុនតូច និង មធ្យម និង យុទ្ធសាស្ត្រផ្សេងៗ ដែលពាក់ព័ន្ធ, គួបផ្សំនឹងធ្វើការសិក្សាយ៉ាងលម្អិតអំពីសមត្ថភាពក្នុងការស្រូបយក, ការត្រៀមខ្លួន (Digital and Industry 4.0 Readiness), ការរាំងស្ទះ (Bottlenecks) និង តម្រូវការ (Skill Needs) ក្នុងការចាប់យកបច្ចេកវិទ្យាថ្មី និង ការធ្វើបរិវត្តកម្មឌីជីថលរបស់សហគ្រាសធុនតូច និង មធ្យម និង ឧស្សាហកម្ម | ១០២ | -ក្រ.ឧ.វ.ប.ន<br>-ក.ស.ហ.វ<br>-ក.ប.ទ<br>-ក្រ.កិច្ចការនារី<br>-ក្រ.ពាណិជ្ជកម្ម<br>-ក្រសួង-ស្ថាប័នពាក់ព័ន្ធ | -របាយការណ៍វឌ្ឍនភាពស្តីពី វិធានការនៃការអភិវឌ្ឍសហគ្រាស<br>-ឯកសារស្រាវជ្រាវពីការធ្វើបរិវត្តកម្មឌីជីថលរបស់សហគ្រាស | x | x | x | x | x | x | x | x | x | x | x | x |
| | ពិនិត្យ និងជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម | | | របាយការណ៍វឌ្ឍនភាព | x | x | x | x | x | x | x | x | x | x | x | x |

| ល.រ* | ទិសដៅគោលនយោបាយ / វិធានការគោលនយោបាយគន្លឹះ | ល.ស** | ក្រសួង-ស្ថាប័ន | សូចនាករ សមិទ្ធកម្មគន្លឹះ | ២០២៣ | | | | ២០២៤ | | | | ២០២៥ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| | សិក្សាស្រាវជ្រាវផ្តោតលើ ការវាយតម្លៃការត្រៀមខ្លួនលើកម្រិតឌីជីថល (Digital Readiness Assessments) របស់សហគ្រាសក្នុងការត្រៀមខ្លួន និងការធ្វើបរិវត្តកម្មឌីជីថល | | | ឯកសារស្រាវជ្រាវ | | | x | x | | | x | x | | | x | x |
| | ការសិក្សាស្រាវជ្រាវ និងវិភាគអំពីស្ថានភាពយេនឌ័រក្នុងវិស័យឌីជីថល | | | ឯកសារស្រាវជ្រាវ | | x | x | x | | | | | | | | |
| ២៥ | បង្កើតយន្តការផ្សព្វផ្សាយ, ប្រឹក្សាយោបល់ និងលើកកម្ពស់ការយល់ដឹងអំពីសេដ្ឋកិច្ចឌីជីថល ដែលមានសមត្ថកិច្ចផ្តល់សេវាដោយឥតគិតថ្លៃ ឬក្នុងតម្លៃសមរម្យ ដល់សហគ្រាសណាដែលមានបំណងចាប់យកបច្ចេក-វិទ្យាឌីជីថលក្នុងប្រតិបត្តិការរបស់ខ្លួន | ១០៣ | -ក.ស.ហ.វ<br>-ក្រ.ឧ.វ.ប.ន<br>-ក.ប.ទ<br>-ក្រ.ពាណិជ្ជកម្ម | យន្តការប្រឹក្សាយោបល់អំពីបច្ចេកវិទ្យាឌីជីថលត្រូវបានដាក់ចេញ | x | x | x | x | x | x | x | x | x | x | x | x |
| | រៀបចំសិក្ខាសាលាផ្សព្វផ្សាយពីសេដ្ឋកិច្ចឌីជីថល និងគម្រោងផ្តួចផ្តើមនានារបស់រាជរដ្ឋាភិបាលសម្រាប់ការធ្វើបរិវត្តកម្មសហគ្រាស | | | របាយការណ៍សិក្ខាសាលា | x | | x | | x | | x | | x | | x | |
| ២៦ | ពង្រឹងក្របខណ្ឌ និង/ឬ បន្តសម្រួលយន្តការចុះបញ្ជី និង ការផ្តល់អាជ្ញាបណ្ណតាមថ្នាលបច្ចេកវិទ្យាព័ត៌មានសម្រាប់សហគ្រាស និង ធុរកិច្ចថ្មី គួបផ្សំនឹងយន្តការលើកទឹកចិត្ត ផ្នែកពន្ធ និង មិនមែនពន្ធ ដើម្បីបំពេញភាពស្របច្បាប់ និង ទទួលបានកម្មវិធីគាំទ្រ និង សេវាសាធារណៈសំខាន់ៗពីរាជរដ្ឋាភិបាល | ១០៤ | -ក.ស.ហ.វ<br>-ក្រ.ពាណិជ្ជកម្ម<br>-ក.ប.ទ<br>-ក្រ.ឧ.វ.ប.ន<br>-ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ចំនួនសហគ្រាសត្រូវបានចុះបញ្ជី និងផ្តល់អាជ្ញាបណ្ណ តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន | x | x | x | x | x | x | x | x | x | x | x | x |
| | សម្រួលយន្តការចុះបញ្ជី និងផ្តល់អាជ្ញាបណ្ណតាមប្រព័ន្ធបច្ចេកវិទ្យាសំដៅបង្កើនភាពងាយស្រួលជូនដល់សហគ្រាស | | | របាយការណ៍វឌ្ឍនភាព | x | x | x | x | x | x | x | x | x | x | x | x |
| | រៀបចំយន្តការលើកទឹកចិត្តផ្នែកពន្ធ និងមិនមែនពន្ធដល់សហគ្រាសដើម្បីជំរុញការចុះបញ្ជី និងផ្តល់អាជ្ញាបណ្ណតាមរយៈថ្នាលឌីជីថល | | | យន្តការលើកទឹកចិត្ត | x | x | | | | | | | | | | |

| ល.រ* | ទិសដៅគោលនយោបាយ / វិធានការគោលនយោបាយគន្លឹះ | ល.ស** | ក្រសួង-ស្ថាប័ន | សូចនាករ សមិទ្ធកម្មគន្លឹះ | ២០២៣ | | | | ២០២៤ | | | | ២០២៥ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| | បន្តពង្រីកការផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីយន្តការលើកទឹកចិត្តផ្នែកពន្ធ និងមិនមែនពន្ធដើម្បីជំរុញការចុះបញ្ជី | | | របាយការណ៍ផ្សព្វផ្សាយ | x | x | x | x | x | x | x | x | x | x | x | x |
| ២៧ | បន្តជំរុញ និង លើកកម្ពស់ការអនុវត្តវិធានការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលមានចែងក្នុងយុទ្ធសាស្ត្រស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង យុទ្ធសាស្ត្រផ្សេង ៗ ដែលពាក់ព័ន្ធ | ១០៥ | -ក្រ.ពាណិជ្ជកម្ម<br>-ក.ស.ហ.វ<br>-ក.ប.ទ<br>-ក្រ.ឧ.វ.ប.ន<br>-ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ | របាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តយុទ្ធសាស្ត្រពាក់ព័ន្ធត្រូវបានរៀបចំ | x | x | x | x | x | x | x | x | x | x | x | x |
| | ពិនិត្យ និងតាមដានការអនុវត្តច្បាប់ និងយុទ្ធសាស្ត្រពាក់ព័ន្ធនឹងពាណិជ្ជ-កម្មតាមប្រព័ន្ធអេឡិចត្រូនិក | | | របាយការណ៍វឌ្ឍនភាព | x | x | x | x | x | x | x | x | x | x | x | x |
